**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**និយ័តករគណនេយ្យនិងសវនកម្ម**

លេខ.....០១០........ន. គ. ស .......

ថ្ងៃអង្គារ ១៣កើត ខែ ផល្គុន ឆ្នាំឆ្លូវ ត្រីស័ក ព.ស. ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ១៥ ខែ មីនា ឆ្នាំ ២០២២

# សេចក្តីណែនាំ

## ស្តីពី

## ការអនុវត្តកាតព្វកិច្ចគណនេយ្យនិងសវនកម្ម សម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ

អនុលោមតាមព្រះរាជក្រមលេខ នស/រកម/០៤១៦/០០៦ ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម, អនុក្រឹត្យលេខ៧៩ អនក្រ.បក ចុះថ្ងៃទី១ ខែមិថុនា ឆ្នាំ២០២០ ស្តីពីពិន័យអន្តរការណ៍ចំពោះអំពើល្មើសទៅនឹងច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម និងប្រកាសលេខ៥៦៣ សហវ.ប្រក. ចុះថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២០ ស្តីពីកាតព្វកិច្ចដាក់របាយការណ៍ហិរញ្ញវត្ថុឱ្យរងសវនកម្មឯករាជ្យ និងដើម្បីលើកកម្ពស់តម្លាភាព គណនេយ្យភាព និងភាពអាចទុកចិត្តបាននៃរបាយការណ៍ហិរញ្ញវត្ថុចំពោះគ្រប់ភាគីពាក់ព័ន្ធ **និយ័តករគណនេយ្យនិងសវនកម្ម(ន.គ.ស.)** នៃ **អាជ្ញាធរសេវាហិរញ្ញវត្ថុមិនមែនធនាគារ** មានកិត្តិយសសូមជម្រាបជូនដំណឹងដល់ លោក លោកស្រី ជាប្រធានអង្គភាពមិនស្វែងរកប្រាក់ចំណេញទាំងអស់មេត្តាជ្រាបថា៖ រាជរដ្ឋាភិបាលបានសម្រេចដាក់ឱ្យអនុវត្តកាតព្វកិច្ចគណនេយ្យ និងសវនកម្ម ដូចមានកំណត់នៅក្នុងច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម និងបទប្បញ្ញត្តិពាក់ព័ន្ធជាធរមាន សម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញចាប់ពីឆ្នាំ២០២២ តទៅ។ ដើម្បីអនុវត្តកាតព្វកិច្ចគណនេយ្យនិងសវនកម្មប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព **ន.គ.ស.** សូមធ្វើការណែនាំដល់អង្គភាពមិនស្វែងរកប្រាក់ចំណេញ ដែលហៅកាត់ថា "**អង្គភាព**" ដូចខាងក្រោម៖

១. អង្គភាពត្រូវ ***កាន់បញ្ជីគណនេយ្យ*** និង ***រៀបចំរបាយការណ៍ហិរញ្ញវត្ថុឱ្យបានត្រឹមត្រូវ*** ស្របតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុកម្ពុជាសម្រាប់អង្គភាពមិនស្វែងរកប្រាក់ចំណេញ។ ករណីអង្គភាពអនុវត្តស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ឬស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជាសម្រាប់សហគ្រាសធុនតូចនិងមធ្យម អង្គភាពត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរជាមុនមក **ន.គ.ស.**។

២. អង្គភាពត្រូវ ***ដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ មក ន.គ.ស. តាមពេលវេលាកំណត់*** ដូចខាងក្រោម៖

២.១. អង្គភាពដែលរងសវនកម្មឯករាជ្យតាមច្បាប់ ត្រូវដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុរងសវនកម្មឯករាជ្យរួចមក **ន.គ.ស.** ក្នុងអំឡុងពេល **៦ខែ ១៥ថ្ងៃ** ក្រោយកាលបរិច្ឆេទបិទបញ្ជីគណនេយ្យ ។

២.២. អង្គភាពដែលមិនរងសវនកម្មឯករាជ្យតាមច្បាប់ ត្រូវដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ ក្នុងអំឡុងពេល **៣ខែ ១៥ ថ្ងៃ** ក្រោយកាលបរិច្ឆេទបិទបញ្ជីគណនេយ្យ។

ដោយឡែក ការដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុមក **ន.គ.ស.** សម្រាប់ការិយបរិច្ឆេទឆ្នាំ២០២១ ដែលត្រូវអនុវត្តនៅក្នុងឆ្នាំ២០២២ ត្រូវបានផ្តល់ជូនរយៈពេលបន្ថែមចំនួន៦០(ហុកសិប)ថ្ងៃ។

៣. អង្គភាពត្រូវ ***ស្នើសុំការអនុញ្ញាតពី ន.គ.ស. លើការកំណត់យកថ្ងៃបិទបញ្ជីគណនេយ្យខុសពីថ្ងៃទី៣១ ខែធ្នូ*** ដែលបានកំណត់ដោយច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម។អង្គភាពត្រូវស្នើសុំការអនុញ្ញាតនេះ ឱ្យបានមុនថ្ងៃទី៣០ ខែមិថុនា ឆ្នាំ២០២២ សម្រាប់អង្គភាពដែលបានបង្កើតមុនថ្ងៃជូនដំណឹងនេះ។ ចំពោះអង្គភាពថ្មីបង្កើតឡើងក្រោយ សេចក្តីណែនាំនេះ ត្រូវស្នើសុំមក **ន.គ.ស.** ក្នុងរយៈពេល៣(បី)ខែ គិតចាប់ពីថ្ងៃចុះបញ្ជីជាស្ថាពរជាមួយក្រសួង-ស្ថាប័នមានសមត្ថកិច្ច។



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
គេហទំព័រ : www.acar.gov.kh
អ៊ីម៉ែល : info@acar.gov.kh
ទូរស័ព្ទ ០៨៥ - ២៣ ៨៨២ ១១១
Phone: 023 882 111

៤. អង្គភាពត្រូវ*ជូនដំណឹងមក **ន.គ.ស.** អំពីភាសាដែលបានប្រើនៅក្នុងប្រព័ន្ធគណនេយ្យកុំព្យូទ័រ ឬប្រព័ន្ធកុំព្យូទ័រពាក់ព័ន្ធ* ប្រសិនបើអង្គភាពស្ថិតក្នុងលក្ខខណ្ឌដូចបានកំណត់នៅសារាចរលេខ០០៩ សហវ ចុះថ្ងៃទី០១ ខែកញ្ញា ឆ្នាំ២០២១ ស្តីពី **"ការប្រើប្រាស់ភាសា និងរូបិយប័ណ្ណក្នុងបញ្ជីគណនេយ្យ និងរបាយការណ៍ហិរញ្ញវត្ថុ"** របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ អង្គភាពដែលបានចុះបញ្ជីជាផ្លូវការរួចហើយ ត្រូវជូនដំណឹងអំពីការប្រើប្រាស់ភាសាអង់គ្លេសក្នុងប្រព័ន្ធគណនេយ្យកុំព្យូទ័រ និង/ឬប្រព័ន្ធកុំព្យូទ័រពាក់ព័ន្ធផ្សេងទៀត មក **ន.គ.ស.** ចាប់ពីថ្ងៃចេញសេចក្តីណែនាំនេះ រហូតដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០២២ ជាកំហិត។ សម្រាប់អង្គភាពដែលទើបបង្កើតថ្មី ត្រូវធ្វើការជូនដំណឹងអំពីការប្រើប្រាស់ភាសាអង់គ្លេសក្នុងប្រព័ន្ធគណនេយ្យកុំព្យូទ័រ និង/ឬប្រព័ន្ធកុំព្យូទ័រពាក់ព័ន្ធផ្សេងទៀតមក **ន.គ.ស.** មិនឱ្យហួសរយៈពេល៦០ (ហុកសិប)ថ្ងៃគិតចាប់ពីថ្ងៃដែលអង្គភាព បានចុះបញ្ជីជាស្ថាពរជាមួយក្រសួង-ស្ថាប័នមានសមត្ថកិច្ច។ ការជូនដំណឹងមក **ន.គ.ស.** ត្រូវអនុវត្តតាម សេចក្តីណែនាំមួយដោយឡែក។

៥. អង្គភាពត្រូវ*ប្រើប្រព័ន្ធអនឡាញ (E-Filing System)របស់ **ន.គ.ស.** ដើម្បីដាក់បញ្ជូនរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំរបស់ខ្លួនមក **ន.គ.ស.*** និងត្រូវ*បង់កម្រៃសេវាសាធារណៈសម្រាប់ការទទួលរក្សាទុករបាយការណ៍ហិរញ្ញវត្ថុ* ស្របតាមប្រកាសលេខ០០១ អ.ស.ហ.ប្រ.ក ចុះថ្ងៃទី១២ ខែមករា ឆ្នាំ២០២២ ស្តីពីសេវាសាធារណៈរបស់និយ័តករគណនេយ្យនិងសវនកម្ម។

**"ការខកខាន ឬការយឺតយ៉ាវមិនបានអនុវត្តកាតព្វកិច្ចតាមការកំណត់ខាងលើ អង្គភាពត្រូវរងទោសទណ្ឌដូចមានចែងក្នុងអនុក្រឹត្យលេខ ៧៩ អនក្រ.បក ចុះថ្ងៃទី០១ ខែមិថុនា ឆ្នាំ២០២០ ស្តីពីពិន័យអន្តរការណ៍ចំពោះអំពើល្មើសទៅនឹងច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម"**។

**ន.គ.ស.** នឹងចុះត្រួតពិនិត្យដល់ទីស្នាក់ការ ឬការិយាល័យរបស់អង្គភាព ក្នុងករណីចាំបាច់។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមន្ត្រីនៃ **ន.គ.ស.** តាមរយៈលេខទូរសព្ទនិងតេឡេក្រាម ÷ ០៨១ ៦៤៤ ៦៦៧/ ០៨៥ ៤៤៤ ៤៨៨/ ០៧៧ ៩៦៨ ៣៩៦/ ០៨៩ ៥០៨ ៥៦៧។

**និយ័តករគណនេយ្យនិងសវនកម្ម**ជឿជាក់យ៉ាងមុតមាំថា **លោក លោកស្រីប្រធានអង្គភាព** ទាំងអស់នឹងអនុវត្តតាមខ្លឹមសារនៃសេចក្តីណែនាំនេះ ប្រកបដោយប្រសិទ្ធិភាព និងក្នុងស្មារតីទទួលខុសត្រូវខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ដើម្បីទទួលបានបច្ចុប្បន្នភាពព័ត៌មានអំពីវិស័យនិងវិជ្ជាជីវៈគណនេយ្យ និងសវនកម្ម សូមចូលរួមក្នុង Telegram Channel របស់ **និយ័តករគណនេយ្យនិងសវនកម្ម**

**អគ្គនាយក**

**ប៊ូ ឋារិទ**